# Alameda County Behavioral Health Care Services

## ក្រដាសផ្ដល់ពត៌មានអំពីថ្នាំពេទ្យ: **ក្លូហ្សាពីន/clozapine (Clozaril)**

ក្លូហ្សាពីន គឺជាថ្នាំកែរោគវិកលចរិត។ គេប្រើថ្នាំនេះសំរាប់ព្យាបាលការវង្វេងវង្វាន់ ការឮសំលេង ការរំជើបរំជួល និងការភ័យខ្លាចដែលរួមផ្សំនឹងជម្ងឺភ្លូតអារម្មណ៍ហៅថា Schizophrenia រោគព្រួយចិត្តគិតច្រើននិយាយច្រើន ការព្រួយចិត្ត និងរោគផ្សេងៗទៀត។ បន្ថែមពីនេះ ថ្នាក្លូហ្សាពីនអាចជួយឲ្យគិតឃើញច្បាស់។

ក្លូហ្សាពីន គឺជាថ្នាំដែលមានអនុភាពខុសប្លែកពីថ្នាំកែរោគវិកលចរិតដទៃទៀត។ គេប្រើថ្នាំនេះសំរាប់ព្យាបាលអ្នកជម្ងឺណាដែលមិនទទួល ឬក៏មានប្រតិកម្មយ៉ាងខ្លាំងជាមួយនឹងថ្នាំកែរោគវិកលចរិតដទៃទៀត។ មានអ្នកជម្ងឺខ្លះមិនប្រឆាំង និងត្រូវនឹងថ្នាំ ក្លូហ្សាពីនជាងថ្នាំកែរោគវិកលចរិតដទៃទៀត។

| **មានជាទូទៅ** | **មិនសូវមាន** | **កម្រមាន** |
|---|---|---|
| ការងុយងោក | ការចង្អោរ | សាច់ដុំរឹង/សាច់ដុំរួញរឹង |
| វិលមុខ/ ការខ្វះលំនឹង | គ្រុនក្ដៅ | ការចុះថយចំនួនកោសិកាឈាមស |
| បេះដូងដើរញាប់ | ការច្រាស់ច្រាល | |
| ចេញទឹកមាត់ច្រើន | ការញ័រញាក់ | |
| ស្រវាំងភ្នែក | ឡើងទម្ងន់ | |
| | ប្រកាច់ | |

មានអ្នកជម្ងឺប្រហែល ១-២ % ដែលព្យាបាលនឹងថ្នាំ clozaril ជួបប្រទះនឹងការថយចំនួនកោសិកាឈាមស (agranulocytosis) ដែលអាចបណ្ដាលមានរោគរលាកយ៉ាងធ្ងន់ធ្ងរ ឬរហូតដល់បាត់បង់ជីវិតផងក៏មាន។ ដោយសារតែបញ្ហានៃប្រតិកម្មនេះគេតំរូវឲ្យអ្នកធ្វើតេសឈាមរាល់អាទិត្យ ដើម្បីត្រួតពិនិត្យមើលកោសិកាស។ ការផ្ដល់ថ្នាំរាល់អាទិត្យ អាចធ្វើបាននៅតែឱសថស្ថានប៉ុណ្ណោះ នៅក្រោយពីបូមឈាមហើយ ហើយឱសថស្ថានត្រូវទទួលក្រដាសលទ្ធផលឈាម ដែលមានចំនួនធម្មតា។

**ថ្នាំទាំងនេះត្រូវលេបរាល់ៗថ្ងៃ។ ដោយសារវាធ្វើសកម្មភាពសន្សឹមៗ ដូច្នេះវាត្រូវប្រើរយៈជាច្រើនអាទិត្យ ឬច្រើនខែទំរាំវាមានអនុភាពពេញលេញ។**

CAMBODIAN